នៅពេលដែលក្មេងម្នាក់ទទួលការវិនិច្ឆ័យរោគនៃវិបត្តិវិសាលគមសតិបញ្ញា (autism spectrum disorder -ASD), ឪពុកម្តាយប្រហែលជាជួបប្រទះនូវលំដាប់មួយនៃផ្លូវចិត្ត, រាប់បញ្ចូលទាំង មានអារម្មណ៍ខឹង, ភ្ញាក់ផ្អើល, ស្រងូតស្រងាត់, អារម្មណ៍ធ្វើអ្វីខុស, ឬក៏ហាក់ដូចជា មានតែខ្លួនម្នាក់ឯង។ ឪពុកម្តាយខ្លះមិនជឿអំពីការវិនិច្ឆ័យរោគនេះឡើយ, ឬមានអារម្មណ៍ដូចជាមានអ្វីមកសន្ធប់លើ ដោយពុំដឹងថា វានឹងមានន័យយ៉ាងណាឡើយចំពោះអនាគតនៃកូនរបស់គេ។ ជាញឹកញាប់, ពេលនេះហើយគឺជាពេលដ៏លំបាកមួយចំពោះគ្រួសារ, ដែលមានអារម្មណ៍ពោរពេញទៅដោយសំណួរ និងភាពប្រទាំងគ្នា។

ឪពុកម្តាយជាច្រើន, ជាពិសេសអ្នកទាំងឡាយដែលមិនធ្លាប់ដឹងឮអំពីវិបត្តិសតិបញ្ញា នឹងសាកសួរខ្លួនរបស់គេថា, “ តើខ្ញុំបានធ្វើឲ្យកើតវិបត្តិនេះឬ?” មិនមែនដូច្នោះទេ! ក្មេងៗដែលមានវិបត្តិសតិបញ្ញា គឺកើតមកដោយមានវិបត្តិនេះរួចស្រេច បើមិនយ៉ាងនេះទេបានកើតមកដោយមានភាពអាចឲ្យកើតវិបត្តិនេះ។ ការថែរក្សាបីបាច់មិនល្អ ឬការដាក់វិន័យដោយគ្មានការប៉ិនប្រសប់ មិនបណ្តាលឲ្យកើតវិបត្តិនេះ។ វាគឺមិនមែនជារោគគំនិតប្រាជ្ញាទេ។ ក្មេងៗដែលមានវិបត្តិសតិបញ្ញា គឺមិនមែនកំពុងតែមិនប្រព្រឹត្តឥតត្រឹមត្រូវទេ។

**តើវិបត្តិសតិបញ្ញាជាអ្វីទៅ?**

ការយល់ដឹងអំពីការវិនិច្ឆ័យរោគនៃវិបត្តិវិសាលគមសតិបញ្ញា ASD គឺជាដំណាក់ដំបូងដ៏សំខាន់ណាស់។ ASDs រួមមានទាំង វិបត្តិសតិបញ្ញា, រោគការរាលដាលខ្លាំងនៃវិបត្តិខាងគំនិតនិងប្រាជ្ញា – បើមិនដូច្នោះទេដូចបានបញ្ជាក់ (PDD-NOS) និងនិមិត្តហេតុរោគអាស្ពឺហ្គឺ (Asperger Syndrome) ។ ASDs ទាំងអស់ “រោគការរាលដាលខ្លាំងនៃវិបត្តិខាងគំនិតនិងប្រាជ្ញា” មានន័យថា ផ្នែកជាច្រើននៃការចម្រើនលូតលាស់ត្រូវបានបះពាល់។ ថ្វីបើក្មេងគ្រប់គ្នាដែលមាន ASD គឺខុសៗគ្នាក្តី, តែក្មេងម្នាក់ៗមានការលំបាកក្នុងការប្រាស្រ័យទាក់ទង និងការសហប្រតិបត្តិការក្នុងសង្គម។ ឧទាហរណ៍ខ្លះៗនៃការលំបាកទាំងនោះ អាចមានដូចនៅខាងក្រោមៈ

**ភាពប្លែកខុសគ្នាក្នុងសង្គម**

- មិនមកអោបជិតស្និតដោយសេចក្តីស្រឡាញ់ នៅពេលមកយក, ប៉ុន្តែបង្អោងខ្លួនថយក្រោយជាជាង
- មិនបើកភ្នែកមើលទាក់ទងគ្នា ឬបើកភ្នែកមើលទាក់ទងគ្នាយ៉ាងតិចតួច
- មិនសើចតបពេលឪពុកម្តាយសើចដាក់ ឬ បញ្ចេញសញ្ញាមុខមាត់ផ្សេងទៀត
- មិនសំឡឹងទៅវត្ថុ ឬ ព្រឹត្តិការណ៍ ដែលឪពុកម្តាយសំឡឹងមើល ឬបង្អុលទៅ
- មិនចង្អុលទៅវត្ថុ ឬព្រឹត្តិការណ៍ ដើម្បីឲ្យឪពុកម្តាយសំឡឹងមើលទៅវត្ថុនោះ
- មិននាំយកវត្ថុ ដើម្បីបង្ហាញឪពុកម្តាយគ្រាន់តែដើម្បីរួមជាចំណែក អំពីចំណង់ចិត្តរបស់គាត់
- ជាញឹកញាប់ មិនមានបញ្ចេញសញ្ញាមុខមាត់សមរម្យឡើយ
- មិនអាចដឹងក្នុងអារម្មណ៍ថាអ្វីទៅ ដែលអ្នកឯទៀតអាចគិត ឬមានអារម្មណ៍យ៉ាងណា ដោយសំឡឹងមើលការបញ្ចេញសញ្ញាមុខមាត់របស់គេ
- មិនបង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់ (ការយល់ចិត្ត) ចំពោះអ្នកដ៏ទៃ
- មិនអាចមានមិត្តភ័ក្តិ

**ភាពប្លែកខុសគ្នានៃការប្រាស្រ័យទាក់ទង**

- មិនចេះនិយាយមួយពាក្យ នៅពេលអាយុ 15 ខែ ឬ ឃ្លា 2 ពាក្យ នៅពេលអាយុ 24 ខែ
- និយាយត្រាប់តាមតែពាក្យអ្វីៗ ដែលអ្នកដ៏ទៃនិយាយដោយឥតយល់ន័យរបស់ពាក្យនោះ (ថាតាមពាក្យគេ ឬទន្ទេញត្រាប់តាមពាក្យគេ)

- មិនឆ្លើយតបនៅពេលគេហៅឈ្មោះ, ប៉ុន្តែឆ្លើយតបនឹងសំឡេងផ្សេងទៀត (ដូចជាសូរស៊ីហ្គ្លេឡាន ឬសូរសំឡេងឆ្មាយំ)
- សំដៅចំពោះខ្លួនឯងថាជា“អ្នក-You” ហើយអ្នកឯទៀតថាជា“ខ្ញុំ-I” (ការនិយាយបញ្ច្រាសនៃសព្វនាម)
- ជាញឹកញាប់ ហាក់ដូចជាមិនចង់និយាយប្រាស្រ័យទាក់ទង
- មិនចាប់ផ្តើម ឬមិនអាចសន្ទនាគ្នាឲ្យបានតជាប់ជាហូរហែ
- មិនប្រើប្រដាប់ក្មេងលេង ឬវត្ថុអ្វីផ្សេងទៀត ដើម្បីជាតំណាងមនុស្ស ឬជីវិតពិតប្រាកដនៅពេលតាំងក្លែងលេងរឿងសំដែង
- អាចមានការចងចាំដោយធ្វើតាមបានល្អ, ជាពិសេសដូចជា លេខ, ចំរៀង, ពាក្យស្លោកឃ្លាខ្លីៗតាមទូរទស្សន៍
- បាត់បង់ដំណាក់ការសំខាន់ខាងភាសា, តាមធម្មតានៅរវាងអាយុ 15 ទៅ 24 ខែ នៅក្នុងក្មេងមួយចំនួនតិច (ការថយក្រោយ)

**ភាពខុសប្លែកខាងឥរិយាបទ (ការមាក់ងាយ, ការធ្វើជាដដែលៗ, និងគំរូយ៉ាងតឹងរឹង)**

- យោលទៅយោលមក, បង្វិល, ធ្វើឲ្យយោល, បង្វិលម្រាមដៃ, ឬទទះដៃ (ឥរិយាបទមាក់ងាយ)
- ចូលចិត្តការធ្វើដដែលៗ, ជាលំដាប់, និងការធ្វើជាទម្លាប់
- នឹកឃើញអំពីសកម្មភាពខ្លះៗជាប់ជានិច្ច, ធ្វើកិច្ចការជាដដែលៗក្នុងកំឡុងពេលថ្ងៃ
- លេងជាមួយប្រដាប់ក្មេងលេងជាផ្នែកៗ ជាជាងលេងប្រដាប់លេងទាំងមូល (ឧទាហរណ៍, បង្វិលកង់ឡាននៃប្រដាប់ក្មេងលេង)
- អាចមានការស្ទាត់ជំនាញដែលបែកចេញពីក្រុមធំៗ, ដូចជា មានសមត្ថភាពអាននៅអាយុក្មេងវ័យ, ប៉ុន្តែជាញឹកញាប់ដោយឥតយល់ថាវាមានន័យជាយ៉ាងណាឡើយ
- មិនស្រែកយំបើសិនជាមានការឈឺចាប់ ឬហាក់ដូចជាមានការភ័យខ្លាចឡើយ
- អាចឆាប់មានអារម្មណ៍ ឬមិនមានអារម្មណ៍សោះឡើយ ចំពោះ ក្លិន, សំឡេង, ពន្លឺភ្លើង, សារធាតុ, និងការប៉ះ
- ការប្រើមិនធម្មតានៃការមើលឃើញ ឬការសំឡឹងមិនដាក់ភ្នែក—សំឡឹងមើលវត្ថុអ្វីមួយពីជ្រុងមិនធម្មតា
- អាចមានការចាប់អារម្មណ៍មិនធម្មតា ឬដ៏ខ្លាំង ប៉ុន្តែតិចតួច

**តើការវិនិច្ឆ័យរោគមានន័យយ៉ាងណាដែរ អំពីកូនរបស់ខ្ញុំ?**

តាមធម្មតាក្មេងៗដែលមានវិបត្តិសតិបញ្ញា មើលទៅហាក់ដូចជាក្មេងៗដែលគ្មានការចំរើនលូតលាស់ឥតទាន់ពេលនោះទេ។ បើក្មេងម្នាក់មានវិបត្តិសតិបញ្ញា មានការមួម៉ៅខ្លាំងនៅក្នុងហាងលក់ម្ហូប, មនុស្សប្រហែលជាសំឡឹងមើល, បញ្ចេញយោបល់មិនល្អ ឬមិនយល់អំពីឥរិយាបទនេះឡើយ។ ញាតិសន្តាន និងសូម្បីតែមនុស្សមិនដែលស្គាល់ អាចមានអារម្មណ៍ផ្តល់នូវយោបល់ដែលគ្មានប្រយោជន៍ អំពីរឿងមួយដែលគេពុំយល់ឡើយ។ គេអាចប្រាប់ឪពុកម្តាយឲ្យប្រៀនប្រដៅកូន, ឬធ្វើឲ្យកូន “ប្រព្រឹត្តឲ្យសមតាមអាយុរបស់គេ”, ដែលធ្វើឲ្យឪពុកម្តាយគ្មានអារម្មណ៍កក់ក្តៅដើម្បីយកកូនចេញទៅក្រៅឡើយ។ ឪពុកម្តាយអាចជួបប្រទះថា វាពិបាកនឹងពន្យល់អំពីការវិនិច្ឆ័យរោគនៃកូនរបស់គេ សូម្បីតែជាមួយសមាជិកគ្រួសារជិតស្និតក៏ដោយ ឬអាចមិនចង់ចែកឲ្យគេដឹងពីការវិនិច្ឆ័យរោគនេះឡើយ។ ឪពុកម្តាយនៃកូនៗដែលមានវិបត្តិសតិបញ្ញា អាចមានអារម្មណ៍នៅដាច់ឡែកពីមិត្តភ័ក្តិ, ញាតិសន្តាន, និងសហគមន៍របស់គេ។

ឪពុកម្តាយគ្រប់គ្នានៃកូនៗតូចមានការតានតឹងចិត្តក្នុងការរស់នៅរបស់គេ…នៅពេលកូនម្នាក់ត្រូវបានវិនិច្ឆ័យរោគនៃវិបត្តិសតិបញ្ញា, ការនេះបន្ថែមការតានតឹងចិត្តថ្មីទៀត។ កូនរបស់អ្នកអាចពុំមានពាក្យនិយាយ ដើម្បីប្រាប់អ្នកអំពីអ្វីៗដែលនាងចង់បាន ឬកំពុងតែគិតទេ។ កូនរបស់អ្នកអាចមិនយល់ អំពីអ្វីៗដែលអ្នកនិយាយ, ហើយអ្នកទាំងពីរអាចមានអារម្មណ៍សន្តាបចិត្ត។ កូនរបស់អ្នកមិនអាចរកមិត្តភ័ក្តិបាន ដូចជាក្មេងៗឯទៀតមានអាយុដំណាលគ្នា ឬលេងជាមួយប្រដាប់លេងដូចក្មេងឯទៀតឡើយ។ កូនរបស់អ្នកអាច

មានឥរិយាបទគួរឲ្យតានតឹងចិត្តនៅពេលបរិភោគម្ហូបអាហារ, នៅលើឡានបឺស, នៅក្នុងហាងលក់ដូរ, នៅក្នុងឡាន, ឬនៅពេលចូលដំណេក។ ទាំងអស់នៃការទាំងនេះ, ដែលជាការធម្មតាសំរាប់ក្មេងៗមានវិបត្តិសតិបញ្ញា, អាចជាការនឿយណាយផ្នែកកំឡាំងកាយនិងកំឡាំងចិត្តចំពោះគ្រួសារ។ សមត្ថភាពរបស់យើងដើម្បីយល់អំពីកូនរបស់អ្នក, ការវិនិច្ឆ័យរោគរបស់គាត់, និងសេចក្តីត្រូវការពិសេសរបស់គាត់ នឹងជួយអ្នកឲ្យស្វែងរកការបំរើយ៉ាងត្រឹមត្រូវ ដើម្បីប្រឈមមុខចំពោះឧបសគ្គបែបដូច្នោះ។

វិបត្តិសតិបញ្ញា, វិបត្តិវិសាលគមសតិបញ្ញា, រោគការរាលដាលខ្លាំងនៃវិបត្តិខាងគំនិតនិងប្រាជ្ញា (PDD) គឺជាឈ្មោះដែលវេជ្ជបណ្ឌិតប្រើ ដើម្បីរៀបរាប់អំពីបញ្ហានៃការចម្រើនលូតលាស់យ៉ាងជាក់លាក់ចំពោះក្មេងៗ។ ឈ្មោះគឺគ្រាន់តែជាពាក្យ។ ឈ្មោះទាំងនោះមិនផ្លាស់ប្តូរកូនរបស់អ្នកជាៈ កូនមានសម្រស់ស្អាត, ប្លែកពីគេឡើយ។ ឈ្មោះ ឬស្លាកអាចជាជំនួយក្នុងរបៀបជាច្រើនយ៉ាង។ ឈ្មោះនោះជួយយើងឲ្យយល់ពីអ្វីៗ កំពុងតែកើតឡើងដល់កូនរបស់អ្នក, ហើយឈ្មោះនោះអាចជួយកូនរបស់អ្នកឲ្យទទួលការបំរើផ្នែកការអប់រំ និងពីសហគមន៍ ដែលគាត់ត្រូវការ។

**តើខ្ញុំត្រូវធ្វើអ្វីខ្លះជាបន្ទាប់មកទៀត?**

បន្ទាប់ពីកូនរបស់អ្នកត្រូវបានប៉ាន់ប្រមាណដោយ វេជ្ជបណ្ឌិត, អ្នកចិត្តសាស្ត្រ ឬអ្នកវិជ្ជាជីវៈមានគុណសម្បត្តិផ្សេងទៀត ឬក្រុមអ្នកឯកទេស, អ្នកនឹងទទួលការពន្យល់នៃការវិនិច្ឆ័យរោគ និងរបាយការណ៍ជាលាយល័ក្ខណ៍អក្សរ ដោយមានការឲ្យយោបល់ចំពោះកម្មវិធី និងការព្យាបាលសំរាប់នៅផ្ទះ និងនៅសាលារៀន។ ដោយសារចំណុចខ្លាំង និងឧបសគ្គរបស់ក្មេងគ្រប់គ្នា ប្លែកខុសពីគ្នា, ក្មេងម្នាក់នឹងត្រូវការនូវការលាយចំរុះខុសៗគ្នានៃការអន្តរាគមន៍ និងការបំរើដែលធ្វើតម្រូវជាពិសេសចំពោះការសិក្សារបស់គេម្នាក់និងទម្រង់សង្គម។

ប្រភពព័ត៏មានតាមតំបន់ និងប្រជាជាតិ ព្រមទាំងការគាំទ្រសំរាប់គ្រួសារដែលមាន ASD គឺរាប់ទៅមានចំនួនច្រើនណាស់, ពីព្រោះការកើតមានឡើងនៃវិបត្តិសតិបញ្ញា កំពុងតែកើនឡើងទូទាំងប្រទេស -- និងទូទាំងពិភពលោក។ អ្វីៗក៏ដោយដែលអ្នកអាចដឹង, ត្រូវចងចាំជានិច្ចក្នុងរឿងនេះថាៈ អ្នកមិនមែនតែម្នាក់ឯងនោះទេ។ មានអ្នកវិជ្ជាជីវៈនៅក្នុងប្រព័ន្ធគ្រប់គ្រងជាច្រើន បានធ្វើការយ៉ាងខ្លាំងខ្លាដើម្បីស្វែងរកបុព្វហេតុ, និងការព្យាបាលថ្មី និងមានប្រសិទ្ធិភាពថែមទៀត ព្រមទាំងធនធានសំរាប់មនុស្សដូចគ្រួសាររបស់អ្នក។

ប្រើធនធានទាំងឡាយដែលក្រុមថែរក្សាសុខភាពរបស់អ្នក នឹងពន្យល់អ្នក ហើយជួយអ្នកប្រើប្រាស់បាន។ សាកសួរសំណួរ។ ស្វែងរកយោបល់ និងជំនួយ។ ទាក់ទងមជ្ឈមណ្ឌលគាំទ្រវិបត្តិសតិបញ្ញានៅក្នុងតំបន់របស់អ្នក។ មជ្ឈមណ្ឌលនេះជាភ្នាក់ងារបានបង្កើតជាពិសេស ដើម្បីជួយអ្នក និងគ្រួសាររបស់អ្នកអំពីសំណួរជាច្រើនដែលអ្នកមាន។ គេនឹងធ្វើការជាមួយអ្នកក្នុងការទទួលព័ត៏មាន ដែលអ្នកត្រូវការដើម្បីសំរេចអំពីការថែទាំសុខភាព, ការអប់រំ, កាលៈទេសៈសង្គម និងការកំសាន្ត, ភ្នាក់ងារសហគមន៍, អង្គការ និងការបំរើព្រមទាំងប្រភពផ្តល់ជំនួយប្រាក់កាស។

ថ្វីបើគ្មានអ្នកណាម្នាក់អាចទោះទាយអំពីអនាគតសំរាប់ក្មេងណាម្នាក់, ដោយមានឬដោយគ្មានការវិនិច្ឆ័យរោគនៃវិបត្តិសតិបញ្ញាក្តី, តែសេចក្តីសង្ឃឹមគឺមានភាពត្រចះត្រចង់យ៉ាងខ្លាំង ចំពោះក្មេងៗដែលបានវិនិច្ឆ័យរោគនៅថ្ងៃនេះ ជាជាងដែលពួកគេត្រូវបានវិនិច្ឆ័យរោគដប់ឆ្នាំកន្លងទៅ។